

# ព្រះ ដែលអ្នកមិនទាន់ស្គាល់—តែគួរឲ្យកោតខ្លាច

នៅប្រទេសកម្ពុជាមានព្រះ មានទេវតា និងមានវិញ្ញាណផ្សេងៗ ដែលប្រជាជនគោរព ប៉ុន្តែមានព្រះដ៏ធំមួយ ដែលភាគច្រើនមិនទាន់កោតខ្លាច ទោះបីជាព្រះអង្គហ្នឹងប៉ះពាល់ជីវិតប្រចាំថ្ងៃរបស់យើងក៏ដោយ។ តើព្រះហ្នឹងជានរណា? សូមអាននិងពិចារណា អត្ថបទនេះនឹងជួយពន្យល់ ដោយសង្ខេបផ្នែកខ្លះពីព្រះគម្ពីរបរិសុទ្ធ។

មុនមានផែនដី មុនមានជាតុទាំងបួន មុនមានមនុស្ស គឺមានព្រះហើយ។ ព្រះអង្គបានបង្កើតពិភពលោក និងបង្កើតអ្វីៗសព្វសារពើនៅក្នុងពិភពលោកនេះ ហេតុនេះហើយព្រះអង្គជាព្រះអម្ចាស់នៃស្ថានសួគ៌ និងផែនដី។ ព្រះអង្គមិនគង់នៅក្នុងវិហារ ដែលមនុស្សធ្វើ ហើយមិនត្រូវការដៃមនុស្សឲ្យថែរក្សា ឬថ្វាយអាហារសែនសោះឡើយ ព្រោះព្រះអង្គទេតើប្រទានឲ្យមនុស្សលោកមានជីវិត មានដង្ហើម និងមានអ្វីៗសព្វសារពើ ព្រះអង្គធ្វើឲ្យថ្ងៃរះបំភ្លឺ ធ្វើឲ្យ



ភ្លៀងធ្លាក់មក ធ្វើឲ្យរុក្ខជាតិដុះឡើង ហើយធ្វើឲ្យសត្វបានច្រើនឡើងដែរ។ ដោយសារព្រះអង្គកំពុងតែទ្រទ្រង់អ្វីៗទាំងអស់ យើងក៏មានអាហារបរិភោគ មានទឹកផឹក និងមានខ្យល់ដកដង្ហើម។

ម្យ៉ាងទៀត ព្រះអង្គបានបង្កើតឪពុកម្ដាយ ដូនតាយើង និងមនុស្សគ្រប់ជាតិសាសន៍ ពីមនុស្សតែម្នាក់ដូច្នេះហើយពួកយើងជាពូជពង្សរបស់ព្រះអង្គ ហើយគួរតែស្វែងរកព្រះអង្គ ប្រសិនបើយើងស្វែងរកព្រះអង្គហ្នឹងមែន នោះពិតជាអាចរកព្រះអង្គនោះឃើញ។ តាមពិតព្រះអង្គមិនគង់នៅឆ្ងាយពីយើងម្នាក់ៗទេ ព្រះអង្គគង់នៅគ្រប់ទីកន្លែង ទាំងក្នុងប្រទេសកម្ពុជាយើង ក្នុងស្រុកយើង ក្នុងភូមិយើង និងនៅក្នុងផ្ទះយើងផង។ ព្រះនេត្រ(ភ្នែក)នៃព្រះអង្គនៅសព្វគ្រប់ទីកន្លែង ក៏អាចមើលឃើញគ្រប់ទាំងអស់បាន ទោះទាំងអាក្រក់ និងល្អផងដែរ។ អ្វីៗដែលយើងធ្វើ អ្វីៗដែលយើងនិយាយ សូម្បីតែអ្វីៗដែលយើងគិត ក៏ព្រះអង្គជ្រាបដឹងទាំងអស់នេះហើយ។ ព្រះអង្គមិនគ្រាន់តែស្គាល់យើងទេ ថែមទាំងព្រះអង្គបានទាក់ទងទៅយើងទៀតផង។

ព្រះជាម្ចាស់បានបង្កើតបទបញ្ញាសំខាន់ពីរយ៉ាងឲ្យយើងធ្វើតាម ទីមួយ គឺ «ត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នក ឲ្យអស់ពីចិត្ត» តើយើងបានគោរពតាមបញ្ញាសំខាន់នេះទេ? តើយើងបានស្រឡាញ់

ព្រះដោយអស់ពីចិត្តទេ? មិនមែនទេ ទោះជាព្រះបានបង្កើតយើងក៏ដោយ យើងមិនបានតម្កើងព្រះអង្គជាព្រះ ទោះជាព្រះផ្គត់ផ្គង់យើងរាល់ថ្ងៃក៏ដោយ យើងមិនបានអរព្រះគុណព្រះអង្គដែរ ផ្ទុយទៅវិញ យើងដូចជាកូនអកត្តញ្ញូ ដែលមិនចេះដឹងគុណឪពុកម្តាយ យើងដូចជាកូនដែលបែកចេញពីឪពុកម្តាយ ហើយមិនដែលអើពើនឹងពួកគាត់ថែមទៀតផង។ ដូចនោះ យើងបានងាកចេញពីព្រះជាម្ចាស់ដើម្បីទៅតាមផ្លូវយើងរៀងខ្លួន ហើយបានបង្កើតព្រះផ្ទាល់ខ្លួនផ្សេងៗ ព្រមទាំងបានគោរពបម្រើរបស់ដែលកើតមកជាជាងដល់ព្រះជាម្ចាស់ដែលបង្កើតរបស់ទាំងនោះវិញ។



មិនតែប៉ុណ្ណោះ ព្រះបង្គាប់ឲ្យយើងធ្វើតាមបទបញ្ញាដ៏សំខាន់ទីពីរដែរ គឺ «ត្រូវស្រឡាញ់អ្នកជិតខាងរបស់អ្នកដូចខ្លួនឯង។» តើយើងបានគោរពតាមបញ្ញាសំខាន់នេះទេ? តើយើងស្រឡាញ់អ្នកដទៃ ដូចស្រឡាញ់ខ្លួនឯងទេ? មិនមែនទេ យើងគិតពីខ្លួនឯងមុនពេលគិតពីពួកគេ ហើយច្រើនដងហើយ យើងបាននិយាយដើមគេ ជេរប្រមាថគេ បោកប្រាស់គេ

ល្បួចគេ ខឹងគេ កុហក់គេ ស្អប់គេ លោភលន់ចង់បានរបស់គេ ហើយសម្លឹងមើលគេដោយចិត្តស្រើបស្រាលនិងតណ្ហា។ បើសិនជាយើងពិនិត្យមើលខ្លួនឯងដោយចិត្តស្មោះ នោះយើងដឹងច្បាស់ថា យើងពិតជាបានប្រព្រឹត្តខុសច្បាប់ចំពោះព្រះមែន ហើយអំពើបាបទាំងអស់នេះ គឺធ្ងន់ធ្ងរ ដោយសារយើងបានធ្វើបាបទាស់នឹងព្រះជាម្ចាស់ នៅចំពោះព្រះនេត្រ(ភ្នែក)របស់ព្រះអង្គ។ តើយើងនឹងរត់ទៅឯណា ឲ្យលាក់កំបាំងពីព្រះភក្ត្រ(មុខ)ព្រះអង្គ?



បើយើងព្យាយាមលាក់ខ្លួន នោះអត់ប្រយោជន៍ទេ គ្មាននរណាម្នាក់ដែលអាចលាក់ពីព្រះភក្ត្រ(មុខ)ព្រះអង្គបានឡើយ គឺទាំងអស់នៅជាអាក្រាតចំពោះព្រះនេត្រ(ភ្នែក)ព្រះអង្គ។ នៅចំពោះព្រះ យើងជាមនុស្សស្មោកគ្រោកដែលពោរពេញដោយអំពើបាប ហើយអស់ទាំងអំពើល្អរបស់យើង ក៏ដូចជាអាវកខ្វក់ហើយ។ យើងមិនអាចលាងសម្អាតបាបរបស់ខ្លួនបានទេ។ ថ្វីបើយើងខំប្រឹងធ្វើល្អជាច្រើនក៏ដោយ វាមិនអាចលុបស្នាមប្រឡាក់នៃបាបរបស់យើងទេ អំពើអាក្រក់របស់យើង

នៅមានកត់ជាប់ចំពោះព្រះភក្ត្រ(មុខ)ព្រះអង្គនៅឡើយ។ តើព្រះជាម្ចាស់ឆ្លើយតបនឹងមនុស្សមានបាបដូចយើងយ៉ាងដូចម្តេច?



ព្រះអង្គឆ្លើយដោយត្រាស់បង្គាប់ដល់មនុស្សលោកទាំងអស់ឲ្យប្រែចិត្តវិញ ព្រោះមានកំណត់ថ្ងៃមួយ ពេលដែលព្រះអង្គនឹងកាត់ទោសនិងជំនុំជម្រះមនុស្សលោកដោយយុត្តិធម៌ ព្រះអម្ចាស់ត្រូវតែដាក់ទោសអស់អ្នកដែលប្រព្រឹត្តអំពើបាប ដោយសារព្រះអង្គស្រឡាញ់សេចក្តីសុចរិត និងស្អប់អំពើអាក្រក់។ នៅថ្ងៃនោះ យើងម្នាក់ៗត្រូវទទួលខុសត្រូវ និងរៀបរាប់ទូលថ្វាយចំពោះចៅក្រមមួយ គឺជាមេចៅក្រមដែលមានគ្រប់ទាំងអំណាចដើម្បីសង្គ្រោះក៏បាន ឬបំផ្លាញក៏បានដែរ។ យើងត្រូវខ្លាចព្រះអង្គហ្នឹង ដែលអាចនឹងបំផ្លាញទាំងព្រលឹង និងរូបកាយបោះទៅក្នុងនរកបាន គឺជាកន្លែងសម្រាប់ទទួលទោសនិងវិនាស



អន្តរាយ។ នៅទីនោះ គេយំសោកដល់ទៅសង្កៀត ធ្មេញជារៀងរហូត ឥតមានអ្នកណាជួយដោះទុក្ខឡើយ។ តើយើងនឹងរត់ទៅឯណា ឲ្យរួចចេញពីការកាត់ទោសនៃនរក? តើយើងនឹងរត់ទៅឯណា ឲ្យរួចចេញពីសេចក្តីក្រោធ(កំហឹង)របស់ព្រះ ដែលត្រូវមកដូច្នេះ?

មានកន្លែងម្លប់តែមួយគត់ ដែលអាចការពារយើងពីកំដៅថ្ងៃ មានទីជ្រកកោនតែមួយគត់ ដែលអាចការពារយើងនៅក្នុងព្យុះខ្លាំង មានព្រះតែមួយគត់ ដែលអាចការពារយើងនៅថ្ងៃនៃសេចក្តីក្រោធ(កំហឹង)។ តើព្រះជានរណា? គឺជាព្រះយេស៊ូវ ដែលបានយាងមកក្នុងពិភពលោក ដើម្បីសង្គ្រោះមនុស្សមានបាប។ តើព្រះយេស៊ូវបានធ្វើអ្វីខ្លះដើម្បីជួយសង្គ្រោះយើង? ព្រះយេស៊ូវបានធ្វើតែអំពើល្អឥតខ្ចោះ ពេញមួយជីវិត ហើយក្រោយនោះបានថ្វាយអង្គទ្រង់ ឲ្យគេសម្លាប់ព្រះអង្គដោយបោះដែកគោលភ្ជាប់នឹងឈើឆ្កាង។ នៅលើឈើឆ្កាងនោះ ព្រះយេស៊ូវ

ដែលមិនធ្វើបាបសោះឡើយ ផ្ទុកបាបរបស់យើង រងទុក្ខទោសរបស់យើង និងសុគតជំនួសយើង គឺអ្នកសុចរិតជំនួសអ្នកទុច្ចរិត។ នៅលើឈើឆ្កាង ព្រះយេស៊ូវបានដោះស្រាយបញ្ហានៃអំពើបាបរបស់យើង ដើម្បីឲ្យយើងទទួលការលើកលែងទោសបាប និងឲ្យយើងមានចិត្តថ្មីដែលស្រឡាញ់សេចក្ដីសុចរិត។



នៅលើឈើឆ្កាង ព្រះយេស៊ូវបានស្រូបយកសេចក្ដីក្រោធ(កំហឹង)របស់ព្រះអង្គ ធ្វើឲ្យព្រះស្ងប់ចិត្តវិញ ដើម្បីឲ្យនាំយើងទៅផ្សះផ្សានឹងព្រះជាម្ចាស់ និងស្គាល់ព្រះយ៉ាងជិតស្និទ្ធជារៀងរហូត។ នេះជារឿងអស្ចារ្យមែន ហើយមានមួយទៀតដែរ!

បន្ទាប់ពីព្រះយេស៊ូវបានរងទុក្ខរហូតដល់មរណភាព គេយកព្រះសពចុះពីឈើឆ្កាង នាំទៅ

បញ្ចុះក្នុងរូងផ្នូរមួយ។ តែបីថ្ងៃក្រោយ ព្រឹត្តិការណ៍ដ៏អស្ចារ្យមួយបានកើតឡើង! ព្រះយេស៊ូវបានរស់ពីស្លាប់ឡើងវិញ ដោយព្រះចេស្ដារបស់អង្គទ្រង់!



ក្រោយនោះ ព្រះអង្គបានលេចមកឲ្យមនុស្សជាច្រើនបានឃើញ បន្ទាប់មកបានឡើងទៅស្ថានសួគ៌ដើម្បីសោយរាជ្យ។ នៅទីនោះ ព្រះយេស៊ូវរង់ចាំពេលវេលាកំណត់ ពេលដែលព្រះអង្គនឹងត្រឡប់មកវិញ ដើម្បីដាក់ទោសមនុស្សមានបាប ហើយសង្គ្រោះអស់អ្នកដែលទទួលជឿព្រះ។

បងប្អូនអើយ ទោះបីអ្នកស្រេកឃ្លានអំពើបាប ឬគិតស្មានថាខ្លួនសុចរិតហើយ ជាការពិត យើងទាំងអស់គ្នាត្រូវការព្រះសង្គ្រោះនេះមែន។ អស់អ្នកដែលមិនព្រមទទួលព្រះយេស៊ូវនៅឡើយ ស្ថិតនៅក្នុងអំពើបាបរបស់ខ្លួនដដែល ហើយត្រូវជាខ្មាំងសត្រូវរបស់

ព្រះអម្ចាស់ ជាព្រះដែលខ្ញាល់(ខឹង)នឹងមនុស្សទុច្ចរិតរាល់ថ្ងៃ។ ចូរឲ្យខ្លាចព្រះអង្គនេះចុះ ដ្បិតអ្នកមិនដឹងសោះឡើយថា ព្រះអង្គនឹងមករកអ្នកនៅពេលណា។ ប៉ុន្តែថ្ងៃនេះ ព្រះអង្គមានបំណងឲ្យមនុស្សទាំងអស់បានសង្គ្រោះ ដូច្នេះព្រះក៏អញ្ជើញយើងម្នាក់ៗមករកព្រះយេស៊ូវ ហើយព្រះអង្គជម្រុញយើងទៀតថា «ចូរផ្សះផ្សានឹងព្រះទៅ ដោយទទួលជឿព្រះអម្ចាស់យេស៊ូវ ចូរប្រែចិត្តពីអំពើដែលនាំឲ្យស្លាប់ ចូរបោះបង់ចោលអំពើបាបទាំងប៉ុន្មានរបស់អ្នក ហើយឲ្យខ្លួនមានចិត្តថ្មី ដ្បិតអ្នករាល់គ្នាចង់ស្លាប់ធ្វើអី? យើងមិនសប្បាយចិត្តនឹងឲ្យនរណាម្នាក់ស្លាប់ទេ ដូច្នេះចូរអ្នកវិលមក ដើម្បីឲ្យបានរស់នៅ។» នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។



បងប្អូនអើយ តើអ្នកបានស្តាប់សំឡេងរបស់ព្រះអម្ចាស់ទេ? សូមយកចិត្តទុកដាក់ចំពោះដំណឹងល្អនេះ ក្រែងអ្នកបាត់ទៅទទួលទោសនិងវិនាសអន្តរាយជារៀងរហូត។ តើយើងនឹងគេចផុតយ៉ាងដូចម្តេចបាន ប្រសិនបើយើងធ្វេសប្រហែសនឹងសេចក្តីសង្គ្រោះដ៏ធំយ៉ាងនេះ? មើល៍ មេចៅក្រមឈរនៅមាត់ទ្វារស្រាប់ហើយ! ព្រះដ៏មានព្រះជន្មរស់ នឹងតបស្នងដល់មនុស្សមានបាប ហើយការដែលធ្លាក់ទៅក្នុងកណ្តាប់ព្រះហស្ត(ដៃ)របស់ព្រះហ្នឹង នោះគួរឲ្យស្ញែងខ្លាចណាស់។ ប៉ុន្តែប្រសិនបើអ្នកប្រែចិត្ត ហើយទទួលជឿព្រះយេស៊ូវ អ្នកមិនចាំបាច់ស្ញែងខ្លាចព្រះហស្ត(ដៃ)របស់ព្រះទៀតទេ ផ្ទុយទៅវិញអ្នកនឹងទទួលមេត្តាករុណានិងការលើកលែងទោសបាបសព្វគ្រប់។



ដូច្នេះ យើងទូន្មានអ្នកថា សូមស្វែងរកព្រះជាម្ចាស់។ សូមអំពាវនាវដល់ព្រះអង្គ ក្នុងកាលដែលព្រះអង្គគង់នៅជិតចុះ។ មើល៍ ឥឡូវនេះហើយ ជាថ្ងៃនៃសេចក្តីសង្គ្រោះ! សូមចូលទៅជិតព្រះដោយអង្វរដូចនេះថា «ឱព្រះអង្គអើយ សូមមេត្តាអត់ទោស

ដល់ទូលបង្គំ(ខ្ញុំ) ដែលជាមនុស្សបាបផង»។ ចូរឲ្យបងប្អូនដឹងជាប្រាកដថា ព្រះអម្ចាស់មានចិត្តសប្បុរសជាបរិបូរ ចំពោះអស់អ្នកណាដែលអំពាវនាវរកព្រះអង្គ ហើយព្រះសន្យាថា «អស់អ្នកដែលអំពាវនាវរកព្រះនាមព្រះអម្ចាស់ អ្នកនោះនឹងបានសង្គ្រោះ»



នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់នៃស្ថានសួគ៌ និងផែនដី ជាព្រះដែលបង្កើតយើង ជាមេចៅក្រមដែលវិនិច្ឆ័យយើង ហើយជាព្រះអង្គសង្គ្រោះដែលអាចជួយសង្គ្រោះយើងឲ្យរួចផុតពីអំពើបាប និងរួចចេញពីថ្ងៃនៃសេចក្តីក្រោធ(កំហឹង)! ព្រះជាម្ចាស់ហ្នឹង គឺជាព្រះដែលយើងគួរឲ្យកោតខ្លាច។

ប្រសិនជាមានសំណួរ សូមទាក់ទងតាមហ្វេសប៊ុក ដោយវាយ
សហាគមន៍ស្វែងរកប្រាជ្ញាព្រះគម្ពីរព្រះយេស៊ូវ
សហាគមន៍ស្វែងរកប្រាជ្ញាព្រះគម្ពីរព្រះយេស៊ូវ
Seeking the Wisdom of Jesus